ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៦០០៥ សហវ.ប្រក

ថ្ងៃ [handwritten] ខែ [handwritten] ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [handwritten] ខែ [handwritten] ឆ្នាំ ២០២០

ប្រកាស
ស្តីពី
ការផ្ទេរឥណទានថវិកា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ ព្រហស្បតិ៍ ០១រោច ខែ បឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២០/០៣៨ ចុះថ្ងៃសុក្រ ១១កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១៧ អនក្រ.បក ចុះថ្ងៃអង្គារ ១៥កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០២០ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១
- បានឃើញអនុក្រឹត្យលេខ ២១៨ អនក្រ.បក ចុះថ្ងៃអង្គារ ១៥កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០២០ ស្តីពីការផ្ទេរឥណទានថវិកា
- តាមការចាំបាច់ដើម្បីអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១

សម្រេច

ប្រការ១ ._

ត្រូវបានប្រតិបត្តិនៅក្នុងវង្វង់ថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ នូវការផ្ទេរឥណទានថវិកាដូចមានបញ្ជាក់ក្នុងតារាងខាងក្រោម៖

និយ័តកម្មចេញពី ៩៩ (ចំណាយមិនទាន់បែងចែកមានមុខសញ្ញា)

ឯកតា៖ លានរៀល

ជំពូក	គណនី	អនុគណនី	បរិយាយ	ច្បាប់ហិ. ឆ្នាំ ២០២១	ឥណទានមុន និយ័តកម្ម	និយ័តកម្ម		ឥណទានថ្មីក្រោយ និយ័តកម្ម
						កើន	ថយ	
			<u>និយ័តកម្មចេញ</u>				**<u>4.893.586</u>**	
			៩៩-ចំណាយមិនទាន់បែងចែក មានមុខសញ្ញា				**4.893.586**	
66			បន្ទុកហិរញ្ញវត្ថុ	621.360	621.360	-	621.360	0
65			ឧបត្ថម្ភរាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់	1.060.450	1.060.450	-	1.060.450	0
65			ការប្រគល់មុខងារអប់រំ និង សុខាភិបាល	824.081	824.081	-	824.081	0
69	6901	69011	ចំណាយមិនបានគ្រោងទុក មានមុខសញ្ញាច្បាស់លាស់	647.000	647.000	-	1.300	645.700
50			ការទូទាត់ប្រាក់ខ្ចីនិងបំណុលប្រហាក់ប្រហែល	1.185.190	1.185.190	-	1.185.190	0
26			ការវិនិយោគ	1.112.105	1.112.105	-	1.112.105	0
27			អចលកម្មហិរញ្ញវត្ថុផ្សេងៗ	89.100	89.100	-	89.100	0
			<u>និយ័តកម្មចូល</u>			**<u>4.893.586</u>**		
			១០-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ			**4.893.586**		
66			បន្ទុកហិរញ្ញវត្ថុ	-	-	621.360	-	621.360
65	6501	65011	ឧបត្ថម្ភធនដល់រាជធានី-ខេត្ត	-	-	14.106,6	-	14.106,6
65	6501	65012	ឧបត្ថម្ភធនដល់ក្រុង-ស្រុក-ខណ្ឌ	-	-	338.095,4	-	338.095,4
65	6501	65013	ឧបត្ថម្ភធនដល់ឃុំ-សង្កាត់	-	-	709.548	-	709.548
65	6501	65016	ឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់ផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ	-	-	824.081	-	824.081
50			ការទូទាត់ប្រាក់ខ្ចីនិងបំណុលប្រហាក់ប្រហែល	-	-	1.185.190	-	1.185.190
26	2601	26012	ការវិនិយោគទុនរួមគ្នា	-	-	1.112.105	-	1.112.105
27	2701	27011	ការឱ្យខ្ចីទៅសហគ្រាសសាធារណៈ	-	-	89.100	-	89.100

ប្រការ២ .-

ឥណទានថវិកាដែលបានផ្ទេរក្នុងប្រការ ១ ខាងលើនេះ ត្រូវបានអនុញ្ញាតឱ្យបំពេញបន្ថែមទៅក្នុងសៀវភៅថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១។

ប្រការ៣ .-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

ចម្លងជូន៖

- អគ្គនាយកដ្ឋានរតនាគារជាតិ
- អគ្គនាយកដ្ឋាន/នាយកដ្ឋានពាក់ព័ន្ធ
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ